# ការណែនាំដើម្បីបង្កើត គម្រោងការណ៍សិក្សាសម្រាប់សិស្សម្នាក់ៗ

**តើ គម្រោងការណ៍សិក្សាសម្រាប់សិស្សម្នាក់ៗ (ILP) គឺជាអ្វី?**

គម្រោងការណ៍សិក្សាសម្រាប់សិស្សម្នាក់ៗ គឺជាឯកសារផ្ទាល់ខ្លួនដែលសិស្សបានគ្រោងរួមគ្នាជាមួយអ្នកផ្តល់ឱវាទនៅសាលារបស់ពួកគេ និងអ្នកផ្តល់ជំនួយផ្សេងទៀត ក្នុងឆ្នាំសិក្សានីមួយៗ។ ILP មានបួនជំពូកគឺៈ

- កំណត់គោលបំណង/Setting Goals
- ស្វែងយល់អំពីឧបស័គ្គដែលរាំង/Identifying Potential Barriers
- ស្វែងយល់អំពីវិធីសាស្រ្តផ្សេងៗដែលធ្វើឲ្យសម្រេចនូវគោលបំណង/Identifying Strategies to Reach Goals
- រៀបចំបញ្ជីកត់សម្គាល់នូវជ័យជំនះ (តាមកម្រិតថ្នាក់)/Preparing for Success Checklists (by grade level)

**តើគោលបំណងរបស់ ILP សម្រាប់អ្វី?**

គោលបំណងរបស់ ILP គឺដើម្បីជួយសិស្សឲ្យចេះធ្វើការឆ្លុះបញ្ចាំងចំពោះខ្លួនឯង និងចេះម្ចាស់ការលើការសិក្សារបស់ខ្លួន។ សិស្សប្រើ ILP ដើម្បីបង្កើតផែនការរបស់ពួកគេ និងត្រួតពិនិត្យមើលពីការរីកចម្រើនរបស់ខ្លួន ដើម្បីសម្រេចតាមគោលបំណងទាំងនោះ។ ILP គឺជាវិធីសាស្រ្តដើម្បីជួយឲ្យសិស្សម្នាក់ៗ ដើរឆ្ពោះទៅកាន់ការបញ្ចប់ការសិក្សា និងដើម្បីសម្រេចថាតើពួកគេត្រូវការអ្វីខ្លះដើម្បីត្រៀមខ្លួនឲ្យមាន ជោគជ័យនៅក្នុងជីវិត។

**តើគេអាចមើល និងប្រើ ILP ដោយរបៀបណា?**

សិស្សអាចមើល ILPs របស់ពួកគេតាមការប្រើកុំព្យូទ័រ StudentNet របស់ពួកគេ (អ្នកផ្តល់ឱវាទជាអ្នកផ្តល់ពាក្យសម្ងាត់)។ សិស្សរៀបគម្រោង ILPs របស់ពួកគេដោយ សរសេរ និងកែសម្រួល លិខិត ILP តាមអ៊ិនធ័រនែត នៅក្នុង StudentNet ដោយផ្ទាល់។ អ្នកផ្តល់ឱវាទ គ្រូបង្រៀន និងបុគ្គលិកសាលាផ្សេងទៀតអាចមើល ILPs ដែលមាននៅក្នុង Schoolnet ចំពោះមាតាបិតាអាចត្រឹមតែមើល ILP របស់កូននៅ ក្នុង FamilyNet តែប៉ុណ្ណោះ។

**តើអ្នកណាជាអ្នកជួយសិស្សជាមួយ ILP?**

អ្នកផ្តល់ឱវាទ គ្រូបង្រៀន និងបុគ្គលិកសាលាផ្សេងទៀត នឹងធ្វើការជាមួយសិស្សដើម្បីជួយ ណែនាំ សម្របសម្រួល និងគាំទ្រ ពួកគេក្នុងការរៀបគម្រោង ILPs របស់ពួកគេ ហើយធ្វើយ៉ាងណាឲ្យសិស្សមើលរបាយការណ៍របស់ពួកគេនៅក្នុង StudentNet ឡើងវិញ និងអាចមើល ILP របស់ពួកគេ នៅពេលសំខាន់ៗ ក្នុងកំឡុងឆ្នាំសិក្សា។

មាតាបិតា/អាណាព្យាបាល ព្រមទាំងដៃគូ នៅក្នុងក្រុង និងនៅក្នុងសហគមន៍ ដែលធ្វើការជាមួយសិស្សក្នុងកម្មវិធី នៅក្នុងឬក្រៅសាលា ក៏បានជំរុញឲ្យជួយ ណែនាំ សម្របសម្រួល និងគាំទ្រ សិស្សក្នុងការប្រើ StudentNet និងការបង្កើត ILPs របស់ពួកគេ។

**តើ ILP និង StudentNet ទាក់ទងគ្នាយ៉ាងដូចម្តេច?**

StudentNet និង ILP ទាំងពីរនេះបានរៀបចំឡើងដើម្បីផ្តល់លទ្ធភាពដល់សិស្ស តាមរយៈការផ្តល់ព័ត៌មាន ជំនួយ និងការចូលរួមផ្ទាល់ជាមួយ អ្នកផ្តល់ឱវាទ និងអ្នកគាំទ្រផ្សេងៗទៀត ក្នុងការរៀបចំផែនការ ដើម្បីឲ្យពួកគេមានជោគជ័យទៅកាន់ការបញ្ចប់ការសិក្សា និងអ្វីៗផ្សេងទៀត។

StudentNet ផ្តល់ឲ្យសិស្ស នូវលទ្ធភាព មើលរបាយការណ៍សិក្សារបស់ពួកគេផ្ទាល់ និងជំនួយជាច្រើនទៀត ដែលអាចជួយពួកគេឲ្យ រៀបចំគម្រោងសម្រាប់ ILPs ដែលមានអត្ថន័យ។

StudentNet និង ILP មានសម្រាប់សិស្សរបស់ក្រសួងអប់រំទាំងអស់ ពីថ្នាក់មត្តេយ្យ ដល់ ទី១២។ សម្រាប់ឆ្នាំសិក្សា ២០១០-២០១១ គឺតម្រូវឲ្យសិស្សថ្នាក់ទី៤ ដល់ទី១២ទាំងអស់ រៀបចំគម្រោងការណ៍សម្រាប់សិក្សារៀងៗខ្លួន និងមើលតាម StudentNet របស់ពួកគេឲ្យបានទៀងទាត់ ដោយមានជំនួយពី អ្នកផ្តល់ឱវាទ គ្រូបង្រៀន និងអ្នកដទៃៗទៀត។

**តើ ILP មានទ្រង់ទ្រាយបែបណា?**

បីជំពូកដំបូងគឺ មានទម្រង់សម្រាប់ចម្លើយគ្មានកំណត់ (open-text response) ដោយគ្មានកំណត់ពាក្យ ឬកម្រិតទ្រង់ទ្រាយ។ សិស្សអាចសរសេរតាមចំណង់ចិត្ត និងរៀបចំទ្រង់ទ្រាយទៅតាមការចង់បានរបស់ខ្លួន។ បញ្ជីផ្ទៀងផ្ទាត់ នៅក្នុងជំពូកនៃកម្រិតថ្នាក់ គឺសម្រាប់តែចម្លើយដែលគូសលើប្រអប់ តែប៉ុណ្ណោះ។

# កំណត់ទិសដៅ/SETTING GOALS

សមាសភាគនៃការកំណត់ទិសដៅ នៃ ILP មានសារៈសំខាន់ណាស់ ពីព្រោះវាផ្តល់នូវមូលដ្ឋានសម្រាប់ផ្នែកផ្សេងៗ នៃផែនការ។ យើងជំរុញឲ្យ សិស្ស និង អ្នកផ្តល់ឱវាទ ប្រើគម្រោង SMART Goals និង/ឬ អ្វីៗដែលបានផ្តល់ឲ្យនៅក្នុងកម្មវិធីសិក្សា ដូចជាការជ្រើសរើសអាជីព ដែលអាចជួយសិស្សរៀបចំគម្រោង ដែលមានអត្ថន័យ សម្រាប់គោលបំណង ក្នុងពេល ខ្លី និងយូរអង្វែង។ សិស្សគួរពិនិត្យមើលរបាយការណ៍សិក្សារបស់ខ្លួន នៅក្នុង StudentNet ដែលបង្ហាញ ឲ្យឃើញនូវចំណុច ខ្លាំងពូកែ និងអន់ខ្សោយ ហើយចូលរួមក្នុងការពិភាក្សាអំពីការកំណត់ទិសដៅ ដែលអាចជួយពួកគេ ឲ្យទទួលជោគជ័យ ក្នុងពេល ខ្លី និង យូរអង្វែង។

ទិសដៅមានអត្ថន័យ បើសិនជាទិសដៅទាំងនេះជា "SMART"៖ កំណត់ច្បាស់លាស់/Specific អាចថ្លឹងថ្លែងបាន/Measurable អាចសម្រេចទៅបាន/ Achievable សមស្រប/សមហេតុសមផល/Relevant/Realistic និង តាមពេលកំណត់/Timed។

**កំណត់ច្បាស់លាស់៖** ទិសដៅដែលអ្នកបានកំណត់ គួរមានភាពក្បោះក្បាយ និងច្បាស់លាស់។ ដូច្នេះ ចៀសជាងនិយាយថា "ខ្ញុំចង់រៀនឲ្យបានពូកែនៅថ្នាក់ទី៧" អ្នកគួរនិយាយថា "ខ្ញុំចង់រៀនឲ្យបានពិន្ទុយ៉ាងហោចណាស់ B+ គ្រប់ថ្នាក់ទាំងអស់ នៅឆ្នាំសិក្សានេះ។"

**អាចថ្លឹងថ្លែងបាន៖** ទិសដៅ SMART អាចថ្លឹងថ្លែងបាន ដើម្បីឲ្យអ្នកដឹងនៅពេលដែលអ្នកបានសម្រេចបំណង។ បើសិនជាអ្នកលេងបាល់បោះ (basketball) ចៀសជាងនិយាយថា "ខ្ញុំចង់លេងឲ្យបានពន្ទុច្រើននៅរដូវនេះ" អ្នកគួរនិយាយថា "ខ្ញុំចង់លេងឲ្យបាន១៥០ពិន្ទុនៅរដូវនេះ។" បែបនេះ អ្នកដឹងច្បាស់នៅពេលដែលអ្នកធ្វើបានសម្រេចតាមគោលបំណងរបស់អ្នក។ ហើយនោះក៏ជាឧទាហរណ៍នៃទិសដៅសម្រាប់រយៈពេលខ្លី។ ទិសដៅយូរអង្វែង សម្រាប់បាល់បោះអាចនិយាយថា៖ "ខ្ញុំចង់ចូលក្នុងក្រុមអ្នកដែលលេងបានពិន្ទុ១០០០ នៅពេលដែលខ្ញុំរៀនចប់។"

អាចសម្រេចទៅបាន៖ ទិសដៅរបស់អ្នកគួរសម្រាប់ធ្វើឲ្យមានការខំប្រឹងប្រែង យើងចង់ឲ្យអ្នកប្រឹងជំរុញខ្លួនឯង។ តែទោះជាយ៉ាងដូច្នេះក្តី ទិសដៅទាំងនេះ គប្បីមានលក្ខណៈសមហេតុសមផល។ "ខ្ញុំចង់បញ្ចប់ការសិក្សាពីវិទ្យាល័យ នៅក្នុងរយៈពេល២ឆ្នាំ" គោលបំណងនេះគឺ មិនសមហេតុសមផលទេ សម្រាប់សិស្សថ្នាក់ទី៩ភាគច្រើន។ "ខ្ញុំចង់បញ្ចប់ការសិក្សានៅ ខែមិថុនា ឆ្នាំ ២០១៤ ដោយបានទទួលប័ណ្ណសរសើរ" ជាទិសដៅដែលមានលក្ខណៈលំបាកមែន ប៉ុន្តែសមហេតុផលជាង សម្រាប់សិស្សថ្នាក់ទី៩។

**សមស្រប/សមហេតុសមផល៖** ដើម្បីរក្សាបាននូវកម្លាំងចិត្ត ទិសដៅរបស់អ្នក គប្បីមានសារៈសំខាន់ចំពោះអ្នក។ គិតមើលឲ្យបានគ្រប់ជ្រុងជ្រោយ។ តើអ្វីដែលមានសារៈសំខាន់ចំពោះអ្នក? តើអ្នកឲ្យតម្លៃវាយ៉ាងដូចម្តេច? បើអ្នកចូលចិត្តតន្ត្រី អ្នកគប្បីកំណត់ទិសដៅ ដើម្បីបង្កើននូវការប៉ិនប្រសប់ខាងដូជន្ត្រីរបស់អ្នក។ បើការទៅរៀននៅមហាវិទ្យាល័យ មានសារៈសំខាន់ចំពោះអ្នក ចូរកំណត់ទិសដៅដែលអាចឲ្យអ្នកត្រៀមខ្លួនជាស្រេចសម្រាប់មហាវិទ្យាល័យ។

**តាមពេលកំណត់៖** ទិសដៅទាំងអស់របស់អ្នក គប្បីមានថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់។ ទិសដៅដែលគ្មានពេលវេលាត្រឹមត្រូវ អាចធ្វើឲ្យអ្នកមិនសូវមានចិត្តចង់ធ្វើឲ្យសម្រេចតាមគោលបំណងនោះ។ ចៀសជាងនិយាយថា "ខ្ញុំចង់តែងបទចម្រៀង" អ្នកគួរកំណត់ទិសដៅដើម្បីនិពន្ធបទចម្រៀងមុនពេលអ្នកមានអាយុ១៧ឆ្នាំ។

**កំណត់ទិសដៅសម្រាប់រយៈពេល ខ្លី និងយូរអង្វែង/Setting Short and Long-Term Goals**

ILP នឹងមានអត្ថន័យយ៉ាងក្រៃលែង ពេលណាសិស្សរៀបចំទិសដៅសម្រាប់រយៈពេល ខ្លី និងយូរអង្វែង។

**ទិសដៅសម្រាប់រយៈពេលខ្លី/Short-term goals** ផ្តោតទៅលើឆ្នាំសិក្សាបច្ចុប្បន្ន។ គិតមើលអំពីទិសដៅពីរប្រភេទសម្រាប់ រយៈពេលខ្លី៖

- ទិសដៅសម្រាប់មុខវិជ្ជាអ្វីមួយ (ឧទាហរណ៍ បង្កើនពិន្ទុពី C ទៅ B សម្រាប់ គណិតវិទ្យា ធ្វើលំហាត់ឲ្យរួចរាល់ទាន់ពេលវេលា ។ល។)
- ទិសដៅសម្រាប់អាកប្បកិរិយា (ឧទាហរណ៍ បង្កើនវត្តមាន ឈប់មករៀនយឺតពេល ។ល។)

មុនដំបូង ពិនិត្យមើលឯកសាររបស់អ្នកនៅក្នុង StudentNet ហើយគិតមើលអំពីអ្វីដែលអ្នកពូកែ អ្វីដែលអន់ខ្សោយ និងអ្វីដែលអ្នកមានចំណាប់អារម្មណ៍។ បន្ទាប់មក ដោយយោងទៅលើឯកសាររបស់អ្នក ត្រូវដឹង និងរៀបរាប់ ពីទិសដៅពិតប្រាកដ សម្រាប់ជោគជ័យ ការធ្វើបានសម្រេច និងការកែលម្អ ដែលជាប់ទាក់ទងនឹងមុខវិទ្យា ការប្រឡង និងសកម្មភាពផ្សេងៗ ដែលអ្នកនឹងចូលរួម នៅក្នុងឆ្នាំសិក្សានេះ។

ក្រោយពីអ្នកបានសម្រេចចិត្តអំពីទិសដៅសម្រាប់រយៈពេលខ្លី របស់អ្នករួចហើយ ធ្វើយ៉ាងណាត្រូវពិនិត្យមើលពីទិសដៅទាំងនោះឡើងវិញ យ៉ាងហោចណាស់រៀងរាល់សប្តាហ៍ ហើយប្រើ StudentNet ដើម្បីមើលការរីកចម្រើនរបស់អ្នកជាបន្តបន្ទាប់។ បើសិនជាអ្នកត្រូវការជំនួយ ដើម្បីធ្វើឲ្យបានសម្រេចនូវគោលបំណងណាមួយ ត្រូវធ្វើគម្រោងការណ៍ដើម្បីរកជំនួយ។ ឧទាហរណ៍ បើអ្នកមានទិសដៅដើម្បីរៀនឲ្យបានពិន្ទុ B+ សម្រាប់ពិជគណិត កម្រិត១ ប៉ុន្តែនៅក្នុងកំឡុងត្រីមាសទី២ មើលទៅអ្នកមិនអាចសម្រេចបានតាមគោលបំណងនេះទេ អ្នកត្រូវធ្វើគម្រោងការណ៍ដើម្បីរកអ្នកជួយបង្រៀនបន្ថែម ឬគ្រាន់ត្រូវ

ជួបជាមួយគ្រូរបស់អ្នកក្រោយម៉ោងរៀន ដើម្បីទទួលការពន្យល់បន្ថែម។ ការពិនិត្យមើលទិសដៅរបស់អ្នកជារឿយៗ អាចជួយអ្នកឲ្យសម្រេចបានតាមគោលបំណងទាំងនោះ។

**ទិសដៅសម្រាប់រយៈពេលយូរអង្វែង/Long-term goals** ផ្ដោតទៅលើអនាគតរបស់អ្នក ក្រោយពេលរៀនចប់ពីវិទ្យាល័យ។

មុនដំបូង ពិនិត្យមើលឯកសាររបស់អ្នកនៅក្នុង StudentNet ហើយគិតមើលអំពីអ្វីដែលអ្នកពូកែ អ្វីដែលអន់ខ្សោយ និងអ្វីដែលអ្នកមានចំណាប់អារម្មណ៍។ បន្ទាប់មក ដោយយោងទៅលើឯកសាររបស់អ្នក ត្រូវដឹង និងរៀបរាប់អំពីទិសដៅ សម្រាប់គោលបំណងថាតើអ្នកចង់ក្លាយខ្លួនទៅជាអ្វី និងចង់ធ្វើអ្វីនៅក្នុងជីវិត--ក្រោយពេលរៀនចប់ពីវិទ្យាល័យភ្លាមៗ នឹងទៅអនាគត។

បន្ទាប់ពីអ្នកបានសម្រេចចិត្តពី ទិសដៅសម្រាប់រយៈពេលយូរអង្វែងរបស់អ្នករួចហើយ ធ្វើយ៉ាងណាត្រូវពិនិត្យទិសដៅទាំងនោះឡើងវិញ ជារឿយៗ ពីដើមឆ្នាំដល់ចុងឆ្នាំ។ ប្រើ StudentNet ដើម្បីពិនិត្យមើលឯកសារនៃការសិក្សារបស់អ្នក រួមទាំងពិន្ទុសរុបដែលរៀនបាន ពិន្ទុ វត្តមានអវត្តមាន ពិន្ទុនៃការប្រឡង ។ល។ សម្រេចថាតើអ្នករៀនបានកម្រិតណា ហើយត្រូវរកជំនួយបើសិនជាអ្នករៀនមិនបានសម្រេចតាមទិសដៅ។ ការពិនិត្យមើលទិសដៅរបស់អ្នកជារឿយៗ អាចជួយអ្នកឲ្យសម្រេចបានតាមគោលបំណងទាំងនោះ។

**សំណួរដែលផ្ដោតទៅលើ ទិសដៅសម្រាប់រយៈពេលខ្លី/Short-term Goal Focus Question៖** *តើខ្ញុំត្រូវធ្វើដូចម្ដេចដើម្បីកែលម្អឯកសារនៃការសិក្សារបស់ខ្ញុំក្នុងឆ្នាំសិក្សានេះ?*

**ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗអំពី ទិសដៅសម្រាប់រយៈពេលខ្លី ដែលអ្នកអាចប្រើ ឬផ្លាស់ប្ដូរ ដើម្បីបង្កើតផែនការផ្ទាល់ខ្លួនរបស់អ្នក៖**

ខ្ញុំនឹងរៀនឲ្យបានឡើងថ្នាក់ទាំងអស់។
ខ្ញុំនឹងបង្កើនពិន្ទុរបស់ខ្ញុំពី ____ ទៅ ____ នៅពេលចែករបាយការណ៍ពិន្ទុលើកក្រោយ សម្រាប់ថ្នាក់ ________ ។
ខ្ញុំនឹងបានពិន្ទុ _______ ដែលជាពិន្ទុចុងក្រោយ សម្រាប់ថ្នាក់ _______ នៅចុងបញ្ចប់ឆ្នាំសិក្សា។
ខ្ញុំនឹងបង្កើន GPA (ពិន្ទុមធ្យមភាគ) របស់ខ្ញុំ ពី___ ទៅ ___ នៅចុងបញ្ចប់ឆ្នាំសិក្សា។
ខ្ញុំនឹងបញ្ចប់ការសិក្សាពីវិទ្យាល័យនៅឆ្នាំនេះ។
ខ្ញុំនឹងទទួលពិន្ទុមធ្យម ឬគ្រាន់បើជាងនេះ នៅលើរបាយការណ៍ពិន្ទុរបស់ខ្ញុំ ក្នុងការខិតខំគ្រប់ថ្នាក់របស់ខ្ញុំទាំងអស់ ។
ខ្ញុំនឹងទទួលពិន្ទុល្អបង្គួរ ឬគ្រាន់បើជាងនេះ ផ្នែកអាកប្បកិរិយា គ្រប់ថ្នាក់របស់ខ្ញុំទាំងអស់។
ខ្ញុំនឹងកែលម្អការប្រឡង PSSA ក្នុងការអាន របស់ខ្ញុំឲ្យបាន Basic/Proficient/Advanced។
ខ្ញុំនឹងកែលម្អការប្រឡង PSSA ក្នុងគណិតវិទ្យារបស់ខ្ញុំឲ្យបាន Basic/Proficient/Advanced។
ខ្ញុំនឹងបង្កើនកម្រិតនៃការអានរបស់ខ្ញុំ យ៉ាងហោចណាស់មួយថ្នាក់ នៅចុងបញ្ចប់ឆ្នាំនេះ។
ខ្ញុំនឹងទៅរៀនឲ្យទាន់ម៉ោងគ្រប់ថ្នាក់ទាំងអស់
ខ្ញុំនឹងទៅរៀនឲ្យបានទៀងទាត់ ហើយអវត្តមានតែម្ដងក្នុងមួយខែ (ដោយមានមូលហេតុត្រឹមត្រូវ)។
ខ្ញុំនឹងធ្វើអ្វីៗគ្រប់បែបយ៉ាងតាមតែអាចធ្វើទៅបាន ដើម្បីផ្ដល់នូវស្ថានភាពល្អ ក្នុងថ្នាក់ និងក្នុងសាលា របស់ខ្ញុំ។
ខ្ញុំនឹងចូលរួមក្នុងសកម្មភាពសិក្សាបន្ថែម។
ខ្ញុំនឹងកែលម្អនូវការប៉ិនប្រសប់ក្នុងការសម្រេចចិត្តរបស់ខ្ញុំ ហើយទទួលគុណវិបត្តិត្រឹមតែ៥ ឬតិចជាង ក្នុងមួយខែ។
ផ្សេងៗ៖

**សំណួរដែលផ្ដោតទៅលើ ទិសដៅសម្រាប់រយៈពេលយូរអង្វែង/Long-term Goal Focus Question៖** *តើខ្ញុំចង់ក្លាយខ្លួនទៅជាអ្វី និងចង់ធ្វើអ្វី នៅក្នុងជីវិតក្រោយពេលចប់ពីវិទ្យាល័យ?*

**ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗនៃការដាស់តឿន ដែលអ្នកអាចប្រើ ដើម្បីបង្កើតទិសដៅសម្រាប់រយៈពេលយូរអង្វែង របស់អ្នក៖**
គោលបំណងសម្រាប់អាជីពរបស់ខ្ញុំគឺ
គោលបំណងផ្ទាល់ខ្លួនរបស់ខ្ញុំគឺ
ខ្ញុំចង់ជួយដល់សហគមន៍របស់ខ្ញុំវិញ ដោយវិធីដូចតទៅនេះ
ខ្ញុំនឹងទៅរៀននៅមហាវិទ្យាល័យ ពីរឆ្នាំ/បួនឆ្នាំ ក្រោយពេលរៀនចប់ពីវិទ្យាល័យ ដើម្បីសិក្សា និងបន្តអាជីពផ្នែក
ខ្ញុំនឹងទៅរៀននៅសាលាបច្ចេកទេស ក្រោយពេលរៀនចប់ពីវិទ្យាល័យ ដើម្បីបន្តអាជីពផ្នែក
ខ្ញុំនឹងចូលធ្វើទាហាន ក្រោយពេលរៀនចប់ពីវិទ្យាល័យ ដើម្បីសិក្សា និងបន្តអាជីពផ្នែក
ខ្ញុំនឹងចូលធ្វើការ ក្រោយពេលរៀនចប់ពីវិទ្យាល័យ ដើម្បីបណ្ដុះបណ្ដាលអាជីពផ្នែក
ផ្សេងៗ៖

# ដឹងពីឧបសគ្គដែលអាចធ្វើឲ្យមានការរារាំង

ក្នុងជំពូកនៃ ILP នេះ កត់សម្គាល់ពីឧបសគ្គដែលអាចរារាំងអ្នកមិនឲ្យសម្រេចតាមគោលបំណង។ ធ្វើយ៉ាងណាត្រូវរកផ្លូវដោះស្រាយឧបសគ្គដែលរារាំងដល់គោលបំណងសម្រាប់រយៈពេល ខ្លី និង យូរអង្វែង ដែលបានកត់សម្គាល់ក្នុងជំពូក នៃការកំណត់ទិសដៅសម្រាប់ ILP។

**សំណួរដែលផ្តោតទៅលើ ឧបសគ្គសម្រាប់ រយៈពេលខ្លី/Short-Term Barriers Focus Question៖** *តើការលំបាកអ្វីខ្លះដែលខ្ញុំត្រូវប្រឈមមុខ ដើម្បីធ្វើឲ្យសម្រេចតាមទិសដៅសម្រាប់រយៈពេលខ្លី របស់ខ្ញុំ?*

**ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗពី ឧបសគ្គដែលប៉ះពាល់ដល់ទិសដៅសម្រាប់រយៈពេលខ្លី ដែលអ្នកអាចប្រើ ឬផ្លាស់ប្តូរ ដើម្បីរៀបចំគម្រោងការណ៍ផ្ទាល់ខ្លួនរបស់អ្នក៖**

ខ្ញុំមិនដឹងពីតម្រូវការដែលខ្ញុំត្រូវធ្វើ ដើម្បីប្រឡងជាប់ថ្នាក់ ដែលខ្ញុំកំពុងរៀន។

ខ្ញុំមិនដឹងពីតម្រូវការដែលខ្ញុំត្រូវធ្វើ ដើម្បីបញ្ចប់ការសិក្សាពីវិទ្យាល័យទេ។

ខ្ញុំត្រូវការរៀនយកពិន្ទុថែមទៀតសម្រាប់មុខវិជ្ជា ______។

ខ្ញុំស្តាប់គ្រូមិនឮទេ។

ខ្ញុំមើលអ្វីៗនៅលើក្តារខៀនមិនឃើញទេ។

នៅក្នុងថ្នាក់រៀន ខ្ញុំអង្គុយជិតសិស្សដែលរំខានដល់ខ្ញុំ។

ខ្ញុំមានភារៈទទួលខុសត្រូវចំពោះក្រុមគ្រួសាររបស់ខ្ញុំ នៅពេលព្រឹក ដែលធ្វើឲ្យខ្ញុំមានការពិបាកនឹងមករៀនឲ្យទាន់ពេលវេលា។

នៅផ្ទះ គ្មានអ្នកណាម្នាក់អាចជួយខ្ញុំធ្វើកិច្ចការដែលគ្រូឲ្យយកមកធ្វើនៅផ្ទះ បានទេ។

ខ្ញុំអត់គេងរហូតដល់យប់ៗជ្រៅ ហើយគេងហួសម៉ោងនៅពេលព្រឹក។

ខ្ញុំមិនដឹងថាមានសកម្មភាពសិក្សាបន្ថែមអ្វីទេ នៅសាលា ឬនៅក្នុងសហគមន៍ របស់ខ្ញុំ។

សាលាបឋមសិក្សា/អនុវិទ្យាល័យ/វិទ្យាល័យ របស់ខ្ញុំ មិនផ្តល់ជំនួយដែលខ្ញុំត្រូវការ។

ផ្សេងៗ៖

**សំណួរដែលផ្តោតទៅលើ ឧបសគ្គសម្រាប់រយៈពេលយូរអង្វែង/ Long-Term Barriers Focus Question៖** *តើការលំបាកអ្វីខ្លះដែលខ្ញុំត្រូវប្រឈមមុខ ដើម្បីធ្វើឲ្យសម្រេចតាមទិសដៅសម្រាប់រយៈពេលយូរអង្វែង របស់ខ្ញុំ?*

**ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗពី ឧបសគ្គដែលប៉ះពាល់ដល់ទិសដៅសម្រាប់រយៈពេលយូរអង្វែង ដែលអ្នកអាចប្រើ ឬផ្លាស់ប្តូរ ដើម្បីរៀបចំគម្រោងការណ៍ផ្ទាល់ខ្លួនរបស់អ្នក៖**

ក្នុងគ្រួសារខ្ញុំ គ្មានអ្នកណាម្នាក់អាចជួយខ្ញុំរកមើលវិធីដាក់ពាក្យចូលរៀននៅមហាវិទ្យាល័យបានទេ។

ក្រុមគ្រួសារខ្ញុំមិនអាចជួយផ្តល់ប្រាក់កាសសម្រាប់រៀននៅមហាវិទ្យាល័យបានទេ។

មិត្តភក្តិរបស់ខ្ញុំបង្ខំឲ្យខ្ញុំឈប់រៀន។

សាលាបឋមសិក្សា/អនុវិទ្យាល័យ/វិទ្យាល័យ របស់ខ្ញុំ មិនផ្តល់កម្មវិធីសិក្សាដែលទាក់ទងនឹងចំណាប់អារម្មណ៍របស់ខ្ញុំទេ។

ផ្សេងៗ៖

# ដឹងអំពីវិធីសាស្ត្រដើម្បីធ្វើឲ្យសម្រេចតាមទិសដៅ

ក្នុងជំពូកនៃ ILP នេះ គឺត្រូវដឹងពីវិធីសាស្ត្រដើម្បីធ្វើឲ្យសម្រេចតាមទិសដៅ សម្រាប់រយៈពេលខ្លី និងយូរអង្វែង របស់អ្នក នឹងរបៀបដែលអ្នកអាចយកជ័យជំនះលើឧបសគ្គ ដែលបានកត់សម្គាល់ក្នុងជំពូកដែលធ្វើឲ្យមានការរារាំង។ ត្រូវបញ្ជាក់ឲ្យចំៗ។ គិតដល់ជំនួយដែលមានទាំងអស់សម្រាប់អ្នក នៅក្នុង សាលា សហគមន៍ ទីក្រុង តំបន់។ល។ ប្រហែលជាមានឧបសគ្គខ្លះដែលអ្នកមិនអាចកែប្រែបាន ឬដែលអ្នកត្រូវការជំនួយពីអ្នកដទៃ ដើម្បីធ្វើឲ្យមានជ័យជំនះ។ ផ្តោតទៅលើឧបសគ្គណាដែលអ្នក**អាច**កែប្រែបាន ហើយត្រូវតែមានសុទិដ្ឋិនិយម ចំពោះចិត្តចង់សម្រេចនូវបំណងប្រាថ្នារបស់អ្នក។

**វិធីសាស្ត្រដើម្បីធ្វើឲ្យសម្រេចតាមទិសដៅសម្រាប់រយៈពេលខ្លី/Strategies for Achieving Short-Term Goals៖** *តើសកម្មភាពអ្វីដែលខ្ញុំត្រូវធ្វើដើម្បីឲ្យសម្រេចតាមទិសដៅសម្រាប់រយៈពេលខ្លី របស់ខ្ញុំ និងដើម្បីយកជ័យជំនះលើឧបសគ្គបាន?*

**ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗពី វិធីសាស្ត្រដែលទាក់ទងនឹងទិសដៅសម្រាប់រយៈពេលខ្លី ដែលអ្នកអាចប្រើ ឬផ្លាស់ប្តូរ ដើម្បីរៀបចំគម្រោងការណ៍ផ្ទាល់ខ្លួនរបស់អ្នក៖**

ខ្ញុំនឹងនិយាយជាមួយគ្រូរបស់ខ្ញុំអំពីតម្រូវការ ដើម្បីទទួលពិន្ទុដែលអាចឡើងថ្នាក់បាន។

ខ្ញុំនឹងពិនិត្យមើលច្បាប់សម្រាប់ បញ្ចប់ការសិក្សា និងឡើងថ្នាក់ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា តាមរយៈ StudentNet។

ខ្ញុំនឹងរៀនបង្គ្រប់ពិន្ទុ សម្រាប់មុខវិជ្ជាណាដែលខ្ញុំត្រូវការ ដោយចុះឈ្មោះក្នុងកម្មវិធីរៀនបង្គ្រប់ពិន្ទុ។

ខ្ញុំនឹងអាននៅផ្ទះសម្រាប់ជាការកំសាន្តរបស់ខ្ញុំ ពី៤ថ្ងៃឡើងទៅក្នុងមួយអាទិត្យ។

ខ្ញុំនឹងចម្លងកិច្ចការដែលគ្រូដាក់ឲ្យយកមកធ្វើនៅផ្ទះ និងធ្វើឲ្យទាន់ពេលវេលាឲ្យបាន យ៉ាងហោចណាស់៨០%។

ខ្ញុំនឹងសុំឲ្យគេជួយ បើសិនជាខ្ញុំមិនយល់អ្វីមួយ។

ខ្ញុំនឹងជួយសិស្សឯទៀត បើសិនជាគេត្រូវការជំនួយ។

ខ្ញុំនឹងសុំគ្រូប្តូរទៅអង្គុយនៅកន្លែងជិតក្តារខៀន។

ខ្ញុំនឹងនិយាយជាមួយគ្រូអំពីការប្តូរកន្លែងអង្គុយ ដើម្បីកុំឲ្យសិស្សរួមថ្នាក់រំខានដល់ខ្ញុំ។

ខ្ញុំនឹងទៅជួបជាមួយគិលានុបដ្ឋាកនៅសាលាអំពីការពិនិត្យ ត្រចៀក/ភ្នែក។

ខ្ញុំនឹងសិក្សាសម្រាប់ ការប្រឡង និង/ឬ ចំណោទសួរ នីមួយៗ ឲ្យបានយ៉ាងហោចណាស់កន្លះម៉ោង។

ខ្ញុំនឹងលើកដៃ យ៉ាងហោចណាស់មួយអាទិត្យម្តង ពេលណាខ្ញុំដឹងចម្លើយទៅនឹងសំណួរដែលគ្រូសួរ។

ខ្ញុំនឹងយកព័ត៌មាន (ពី អ្នកផ្តល់ឱវាទ អ្នកជួយអោយយោបល់ StudentNet របស់ខ្ញុំ ។ល។) និងធ្វើតាមដំណាក់កាលដែលចាំបាច់ ដើម្បីចូលរួមក្នុងសកម្មភាពសិក្សាបន្ថែម ដែលអាចជួយខ្ញុំឲ្យមានការល្អលាស់ និងយល់ដឹងអំពីអ្វីថ្មីៗ។

ខ្ញុំនឹងដាក់ម៉ោងឲ្យនាឡិការោទិ៍ ឬរៀបចំឲ្យអ្នកណាម្នាក់ទូរស័ព្ទមកខ្ញុំ ដើម្បីឲ្យខ្ញុំទៅរៀនទាន់ពេលវេលា។

ខ្ញុំនឹងនិយាយជាមួយអ្នកផ្តល់ឱវាទរបស់ខ្ញុំអំពី ព័ត៌មាន និងជំនួយ ដែលអាចជួយក្រុមគ្រួសាររបស់ខ្ញុំ។

ខ្ញុំនឹងប្រើ StudentNet និង/ឬ ការជួយបង្រៀនបន្ថែម ក្រោយម៉ោងសិក្សា។

ខ្ញុំនឹងធ្វើអ្វីៗដូចតទៅ ដើម្បីទៅរៀនឲ្យទាន់ពេល (សូមមើលក្នុងកិច្ចសន្យាអំពី វត្តមានអវត្តមាន និងការឈប់គេចសាលា)។

ខ្ញុំនឹងប្រើ StudentNet ហើយទាក់ទងទៅ មជ្ឈមណ្ឌលទទួលសិស្សចូលរៀនវិញ ដើម្បីស្រាវជ្រាវ និងរកមើលសាលាដែលអាចបត់បែន តាមសេចក្តីត្រូវការរបស់ខ្ញុំដើម្បីចញ្ចប់ការសិក្សាពីវិទ្យាល័យ នៅពេលដែលខ្ញុំ កំពុងធ្វើការ និង/ឬ មើលថែក្មេង។

ខ្ញុំនឹងរកមើលការផ្លាស់ប្តូរទៅ សាលាបឋមសិក្សា/អនុវិទ្យាល័យ/វិទ្យាល័យ ណាដែលមានជំនួយដែលខ្ញុំត្រូវការ ដើម្បីអាចទទួលបានជោគជ័យ។

ផ្សេងៗ៖

**វិធីសាស្ត្រដើម្បីធ្វើឲ្យសម្រេចតាមទិសដៅសម្រាប់រយៈពេលយូរអង្វែង/ Strategies for Achieving Long-Term Goals៖** *តើសកម្មភាពអ្វីដែលខ្ញុំត្រូវធ្វើដើម្បីឲ្យសម្រេចតាមទិសដៅសម្រាប់រយៈពេលខ្លី របស់ខ្ញុំ និងដើម្បីយកជ័យជំនះលើឧបសគ្គបាន?*

**ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗពី វិធីសាស្ត្រដែលទាក់ទងនឹងទិសដៅសម្រាប់រយៈពេលយូរអង្វែង ដែលអ្នកអាចប្រើ ឬផ្លាស់ប្តូរ ដើម្បីរៀបចំគម្រោងការណ៍ផ្ទាល់ខ្លួនរបស់អ្នក៖**

ខ្ញុំនឹងស្រាវជ្រាវ ហើយរកមើលសាលាណាដែលត្រូវស្ថានភាពរបស់ខ្ញុំ។

ខ្ញុំនឹងធ្វើអ្វីៗដែលចាំបាច់ ដើម្បីធ្វើឲ្យលិខិតដាក់ពាក្យសុំចូលរៀន សាលាបឋមសិក្សា/អនុវិទ្យាល័យ/វិទ្យាល័យ ពិសេសៗ មានលក្ខណៈសំខាន់។

ខ្ញុំនឹងរកមើល ផ្លាស់ប្តូរទៅសាលាណាដែលមានកម្មវិធីសិក្សា ទាក់ទងទៅនឹងចំណាប់អារម្មណ៍របស់ខ្ញុំ។

ខ្ញុំនឹងរកមើលមនុស្សពេញវ័យណាដែលអាចធ្វើជា អ្នកជួយបង្ហាត់បង្ហាញដើម្បីបញ្ចប់ការសិក្សា ដើម្បីផ្តល់ការណែនាំ និងជំនួយ សម្រាប់ ឲ្យការសិក្សារបស់ខ្ញុំទទួលបានជោគជ័យ (សូមមើលវិបសៃ www.phillygradcoach.org)

ខ្ញុំនឹងខិតខំសិក្សាឲ្យអស់ពីសមត្ថភាព ដោយចូលរួមក្នុង កម្មវិធីសិក្សាកម្រិតខ្ពស់ និង/ឬ កម្មវិធីសិក្សាសម្រាប់យកពិន្ទុពីរកន្លែង ដើម្បីអាចទទួលពិន្ទុសម្រាប់មហាវិទ្យាល័យ។

ខ្ញុំនឹងខិតខំសិក្សាឲ្យអស់ពីសមត្ថភាពដោយរៀន មុខវិជ្ជាកម្រិតខ្ពស់ (Calculus, Physics, Spanish 4 ។ល។)។

ខ្ញុំនឹងចូលរួមក្នុងកម្មវិធីរៀនធ្វើជាអ្នកដឹកនាំ។

ខ្ញុំនឹងរកមើលជំនួយ ដើម្បីកែលម្អវិធីសិក្សារបស់ខ្ញុំ។

ខ្ញុំនឹងស្រាវជ្រាវ យ៉ាងហោចណាស់អំពីអាជីពបីខុសៗគ្នា ហើយរកមើល ការសិក្សា/ការហ្វឹកហ្វឺន ដែលត្រូវការសម្រាប់អាជីពនីមួយៗ។

ខ្ញុំនឹងរកមើលអ្នកដែលមានអាជីពដែលខ្ញុំកំពុងស្រាវជ្រាវ ហើយណាត់ពេលនិយាយជាមួយពួកគេ ដើម្បីឲ្យខ្ញុំដឹងកាន់តែច្រើនអំពី ជំនាញទាំងនេះ។

ខ្ញុំនឹងស្រាវជ្រាវរកឱកាសដើម្បីទៅរៀននៅមហាវិទ្យាល័យ ក្រោយពេលរៀនចប់ពីវិទ្យាល័យ។

ខ្ញុំនឹងស្រាវជ្រាវរកឱកាសដើម្បីចាប់ផ្តើមអាជីព ក្រោយពេលរៀនចប់ពីវិទ្យាល័យ ឧ. តាមរយៈការងារដំបូង រៀនធ្វើការជាមួយអ្នកឯកទេស រៀនធ្វើការយកបទពិសោធន៍ កិច្ចការស៊ីវិល កម្មវិធី City Year ។ល។

ខ្ញុំនឹងស្រាវជ្រាវរកឱកាសដើម្បីទទួលការសិក្សានៅវិទ្យាស្ថានជាន់ខ្ពស់ តាមរយៈការចូលបម្រើកងទ័ព។

ខ្ញុំនឹងចូលរួមក្នុងសិក្ខាសាលាស្តីអំពីប្រាក់ជំនួយពីរដ្ឋ ដើម្បីឲ្យដឹងពីវិធីដែលខ្ញុំអាចបង់ថ្លៃរៀននៅមហាវិទ្យាល័យ។

ខ្ញុំនឹងប្រើ វិបសៃដើម្បីជួយរកអាហារូបករណ៍ ដើម្បីឲ្យដឹងអំពីឱកាសសុំប្រាក់ជំនួយ និងអាហារូបករណ៍។

ខ្ញុំនឹងបំពេញពាក្យសុំប្រាក់ជំនួយពីរដ្ឋសហព័ន្ធសម្រាប់បង់ថ្លៃរៀននៅមហានិងសាកលវិទ្យាល័យ ដើម្បីអាចទទួលប្រាក់ជំនួយពីរដ្ឋ សម្រាប់ទៅរៀននៅមហាវិទ្យាល័យ។

ផ្សេងៗ៖

## បញ្ជីផ្ទៀងផ្ទាត់ដើម្បីត្រៀមខ្លួនសម្រាប់ទទួលបានជោគជ័យ

ជំពូកនេះផ្តល់នូវបញ្ជីផ្ទៀងផ្ទាត់ជាច្រើន បែងចែកកម្រិតថ្នាក់ ផ្តោតទៅលើសកម្មភាពតាមដំណាក់កាលដែលសិស្សអាចធ្វើ ដោយមានជំនួយពី ក្រុមគ្រួសារ និងពីសហគមន៍ ដើម្បីជាមូលដ្ឋានឲ្យទទួលបានជោគជ័យ។ គោលបំណងនៃបញ្ជីផ្ទៀងផ្ទាត់ទាំងនេះ គឺដើម្បីធ្វើយ៉ាងណាឲ្យការសម្រេចចិត្តសំខាន់ៗ ត្រូវតាម«ទិសដៅ» របស់សិស្សគ្រប់រូប។

ជំពូកនៃ ILP នេះមានទ្រង់ទ្រាយសម្រាប់គូសយកចម្លើយក្នុងប្រអប់តែប៉ុណ្ណោះ។ បើសិនជាត្រូវការចម្លើយដែលក្បោះក្បាយទៅនឹងប្រការណាំមួយ គេអាចផ្តល់ឲ្យនៅក្នុងជំពូកនៃ ILP ផ្សេងទៀត។ សិស្សគួរពិនិត្យ និងឆ្លើយនូវប្រការទាំងអស់ដែលមាននៅកម្រិតថ្នាក់របស់ខ្លួន។ សិស្សអាចកែបន្ថែមបន្ថយចម្លើយរបស់ពួកគេនៅក្នុងជំពូកនេះ នៅពេលណាក៏បាន។

# បឋមសិក្សា (ថ្នាក់មត្តេយ្យ ដល់ ទី៥)

ខ្ញុំចូលរួមក្នុងសកម្មភាពសិក្សាបន្ថែមដែលផ្តោតទៅលើ (គូសអ្វីៗដែលត្រូវតាមស្ថានភាពរបស់អ្នក)៖

- ☐ អត្តពលកម្ម/Athletics
- ☐ ការសិក្សា/Academics
- ☐ សិល្បៈ/Arts
- ☐ បម្រើសង្គម/Community Service
- ☐ ការបណ្តុះបណ្តាលឲ្យក្លាយជាអ្នកដឹកនាំ/Leadership Development
- ☐ ផ្សេងៗ/Other
- ☐ គ្មានអ្វីសោះ/None
- ☐ ខ្ញុំនឹងនិយាយជាមួយអ្នកផ្តល់ឱវាទ និងអ្នកដទៃទៀត ហើយមើលក្នុង StudentNet ដើម្បីរកមើលសកម្មភាពសិក្សាបន្ថែម ដែលមាន/ I will talk to my Counselor and others, and will visit StudentNet, to find out what extracurricular activities are available

វិធីដែលខ្ញុំអាចរៀនបានតាមកម្រិតថ្នាក់ (គូសអ្វីៗដែលត្រូវតាមស្ថានភាពរបស់អ្នក)៖

- ☐ ការជួយបង្រៀនបន្ថែមក្រោយម៉ោងរៀន/After-school tutoring
- ☐ រៀននៅរដូវក្តៅ ដើម្បីអាចឡើងថ្នាក់បាន/Attending summer school for promotion
- ☐ រៀននៅរដូវក្តៅ ដើម្បីការយល់ដឹងបន្ថែម/Attending summer school for enrichment
- ☐ អានដោយខ្លួនឯង/Reading on my own
- ☐ មើលក្នុង StudentNet ឲ្យបានទៀងទាត់ ដើម្បីពិនិត្យមើលឯកសារសិក្សារបស់ខ្ញុំ និងរកមើលជំនួយផ្សេងៗទៀត/Visiting StudentNet regularly to review my academic record and explore other resources
- ☐ ពិនិត្យមើល ILP របស់ខ្ញុំឲ្យបានទៀងទាត់ ដើម្បីឲ្យដឹងពីការរីកចម្រើន ធ្វើការសម្រេចបើសិនជាខ្ញុំត្រូវការជំនួយ និងធ្វើការកែប្រែបើសិនជាចាំបាច់/ Reviewing my ILP regularly to check progress, determine if I need help, and make updates if necessary
- ☐ ផ្សេងៗ/Other

ដំណាក់កាលបន្ទាប់របស់ខ្ញុំ ក្រោយពេលរៀនចប់ពីវិទ្យាល័យ (គូសយកអ្វីៗដែលត្រូវតាមស្ថានភាពរបស់អ្នក)៖

- ☐ ទៅរៀននៅមហាវិទ្យាល័យ/College
- ☐ ទៅរៀននៅសាលាបច្ចេកទេស/Technical school
- ☐ ចូលធ្វើទាហាន/Military
- ☐ ចូលធ្វើការ/Employment
- ☐ ផ្សេងៗ/Other

# អនុវិទ្យាល័យ (ថ្នាក់ទី៦-៨)

**ខ្ញុំចូលរួមក្នុងសកម្មភាពសិក្សាបន្ថែមដែលផ្តោតទៅលើ (គូសអ្វីៗដែលត្រូវតាមស្ថានភាពរបស់អ្នក)៖**

- ☐ ការសិក្សាផ្នែកអត្តពលកម្ម/Athletics Academics
- ☐ សិល្បៈ/Arts
- ☐ ការបម្រើសហគមន៍/Community Service
- ☐ ការបណ្តុះបណ្តាលឲ្យទៅជាអ្នកដឹកនាំ/Leadership Development
- ☐ ផ្សេងៗ/Other
- ☐ គ្មានអ្វីសោះ/None
- ☐ ខ្ញុំនឹងនិយាយជាមួយអ្នកផ្តល់ឱវាទ និងអ្នកដទៃទៀត ហើយមើលក្នុង StudentNet ដើម្បីរកមើលសកម្មភាពសិក្សាបន្ថែម ដែលមាន/ I will talk to my Counselor and others, and will visit StudentNet, to find out what extracurricular activities are available

**វិធីដែលខ្ញុំអាចរៀនបានតាមកម្រិតថ្នាក់ (គូសអ្វីៗដែលត្រូវតាមស្ថានភាពរបស់អ្នក)៖**

- ☐ រកការជួយបង្រៀនបន្ថែម ក្រោយម៉ោងសិក្សា/After-school tutoring
- ☐ រៀននៅរដូវក្តៅ ដើម្បីអាចឡើងថ្នាក់បាន/Attending summer school for promotion
- ☐ រៀននៅរដូវក្តៅ ដើម្បីការយល់ដឹងបន្ថែម/Attending summer school for enrichment
- ☐ អានដោយខ្លួនឯង/Reading on my own
- ☐ មើលក្នុង StudentNet ឲ្យបានទៀងទាត់ ដើម្បីពិនិត្យមើលឯកសារសិក្សារបស់ខ្ញុំ និងរកមើលជំនួយផ្សេងៗទៀត/Visiting StudentNet regularly to review my academic record and explore other resources
- ☐ ពិនិត្យមើល ILP របស់ខ្ញុំឲ្យបានទៀងទាត់ ដើម្បីឲ្យដឹងពីការរីកចម្រើន ធ្វើការសម្រេចបើសិនជាខ្ញុំត្រូវការជំនួយ និងធ្វើការកែប្រែបើសិនជាចាំបាច់/ Reviewing my ILP regularly to check progress, determine if I need help, and make updates if necessary
- ☐ ផ្សេងៗ/Other

**គម្រោងការណ៍របស់ខ្ញុំគឺទៅរៀននៅវិទ្យាល័យ (គូសអ្វីៗដែលត្រូវតាមស្ថានភាពរបស់អ្នក)៖**

- ☐ ក្នុងតំបន់/Neighborhood
- ☐ ក្នុងតំបន់ (ដែលនៅសង្កាត់ផ្សេង)/Neighborhood (in another zone)
- ☐ សាលាដែលទទួលយកសិស្សទូទាំងក្រុង/Citywide Admission
- ☐ សាលាដែលទទួលយកសិស្សដែលមានលក្ខណៈពិសេស/Special Admission
- ☐ សាលាឆាទ័រ/Charter
- ☐ សាលាដែលគ្រប់គ្រងដោយក្រុមសាសនា/Parochial
- ☐ រៀននៅផ្ទះ/Home schooling
- ☐ ផ្សេងៗ/Other
- ☐ មិនទាន់ដឹងនៅឡើយទេ ប៉ុន្តែនឹងស្វែងរកជំនួយពីអ្នកផ្តល់ឱវាទ និងអ្នកដទៃទៀត ហើយនឹងមើលក្នុង StudentNet ដើម្បីស្រាវជ្រាវរកមើលសាលារបស់ក្រសួងអប់រំ/ Don't know yet, but will seek help from my Counselor and others, and will visit StudentNet to research District schools

**ជំណាក់កាលបន្ទាប់របស់ខ្ញុំ ក្រោយពេលរៀនចប់ពីវិទ្យាល័យ (គូសយកអ្វីៗដែលត្រូវតាមស្ថានភាពរបស់អ្នក)៖**

- ☐ ទៅរៀននៅមហាវិទ្យាល័យ/College
- ☐ ទៅរៀននៅសាលាបច្ចេកទេស/Technical school
- ☐ ចូលធ្វើទាហាន/Military
- ☐ ចូលធ្វើការ/Employment
- ☐ ផ្សេងៗ/Other

# វិទ្យាល័យ (ថ្នាក់ទី៩-១២)

**ខ្ញុំរៀនបានតាមកំណត់ទៅកាន់ការបញ្ចប់ការសិក្សា/ I am on-track to graduate**

- ☐ ពាក់កណ្តាលឆ្នាំ (ខែកុម្ភៈ)/Mid-year (February)
- ☐ នៅចុងបញ្ចប់នៃឆ្នាំសិក្សានេះ (ខែមិថុនា)/At the end of this school year (June)
- ☐ នៅចុងបញ្ចប់ការសិក្សានៅរដូវក្តៅ (ខែកក្កដា)/At the end of summer school (July)
- ☐ ក្នុងរយៈពេលពីរឆ្នាំ/In two years
- ☐ ក្នុងរយៈពេលបីឆ្នាំ/In three years
- ☐ ក្នុងរយៈពេលបួនឆ្នាំ/In four years
- ☐ ក្នុងរយៈពេលលើសពីបួនឆ្នាំ/In more than four years
- ☐ មិនដឹងប្រាកដ ហើយនឹងស្វែងរកជំនួយពីអ្នកផ្តល់ឱវាទរបស់ខ្ញុំ/ Not sure and will seek help from my Counselor

**វិធីដែលខ្ញុំអាចរៀនបានតាមកម្រិតថ្នាក់ (គូសអ្វីៗដែលត្រូវតាមស្ថានភាពរបស់អ្នក)៖**

- ☐ រកការជួយបង្រៀនបន្ថែម ក្រោយម៉ោងសិក្សា/After-school tutoring
- ☐ រៀននៅរដូវក្តៅ ដើម្បីអាចឡើងថ្នាក់បាន/Attending summer school for promotion
- ☐ រៀននៅរដូវក្តៅ ដើម្បីយល់ដឹងបន្ថែម/Attending summer school for enrichment
- ☐ អានដោយខ្លួនឯង/Reading on my own
- ☐ មើលក្នុង StudentNet ឲ្យបានទៀងទាត់ ដើម្បីពិនិត្យមើលឯកសារសិក្សារបស់ខ្ញុំ និងរកមើលជំនួយផ្សេងៗទៀត/Visiting StudentNet regularly to review my academic record and explore other resources
- ☐ ពិនិត្យមើល ILP របស់ខ្ញុំឲ្យបានទៀងទាត់ ដើម្បីឲ្យដឹងពីការរីកចម្រើន ធ្វើការសម្រេចបើសិនជាខ្ញុំត្រូវការជំនួយ និងធ្វើការកែប្រែបើសិនជាចាំបាច់/Reviewing my ILP regularly to check progress, determine if I need help, and make updates if necessary
- ☐ ផ្សេងៗ/Other
- ☐ សហការជាមួយអ្នកជួយបង្ហាត់បង្រៀនដើម្បីបញ្ចប់ការសិក្សា ឲ្យគាត់ផ្តល់ការណែនាំ និងជំនួយដើម្បីឲ្យការសិក្សារបស់ខ្ញុំទទួលបានជោគជ័យ/Working with a Graduation Coach to provide mentorship and support for my academic success (មើលវិបសៃ www.phillygradcoach.org)
- ☐ ផ្សេងៗ/Other

**ខ្ញុំចូលរួមក្នុងសកម្មភាពសិក្សាបន្ថែមដែលផ្តោតទៅលើ (គូសអ្វីៗដែលត្រូវតាមស្ថានភាពរបស់អ្នក)៖**

- ☐ អត្តពលកម្ម/Athletics
- ☐ ការសិក្សា/Academics
- ☐ សិល្បៈ/Arts
- ☐ ការបម្រើសហគមន៍/Community Service
- ☐ ការបណ្តុះបណ្តាលឲ្យក្លាយជាអ្នកដឹកនាំ/Leadership Development
- ☐ ការងារមិនពេញម៉ោង/ Part-time Job
- ☐ ផ្សេងៗ/Other
- ☐ គ្មានអ្វីសោះ/None
- ☐ ខ្ញុំនឹងនិយាយជាមួយអ្នកផ្តល់ឱវាទ និងអ្នកដទៃទៀត ហើយនឹងមើលក្នុង StudentNet ដើម្បីរកមើលសកម្មភាពសិក្សាបន្ថែម ដែលមាន/ I will talk to my Counselor and others, and will visit StudentNet, to find out what extracurricular activities are available

**ខ្ញុំនឹងរៀនក្នុងកម្មវិធីតាមទម្រង់ផ្សេងទៀត ដើម្បីបញ្ចប់ការសិក្សា (គូសអ្វីៗដែលត្រូវតាមស្ថានភាពរបស់អ្នក ឬរើសយកប្រអប់ចុងក្រោយបង្អស់ បើគ្មានអ្វីត្រូវតាមស្ថានភាពទេ)៖/ I will take an alternative pathway to graduation (check all that apply, or select last box if none apply):**

- ☐ វិទ្យាល័យដែលរៀនលឿន/Accelerated High School
- ☐ កម្មវិធីរៀនយកសញ្ញាប័ត្រ GED/ GED Program
- ☐ វិធីចូលរៀននៅមហាវិទ្យាល័យ/ Gateway to College
- ☐ កម្មវិធីជ្រើសរើសការសិក្សា/Educational Options Program (EOP)
- ☐ កម្មវិធី Oasis/Oasis Program

- ☐ ផ្សេងៗ/Other
- ☐ ខ្ញុំនឹងនិយាយជាមួយអ្នកផ្តល់ឱវាទរបស់ខ្ញុំ និង/ឬ ទៅកាន់មជ្ឈមណ្ឌលទទួលសិស្សចូលរៀនវិញរបស់ក្រសួងអប់រំ ដើម្បីឲ្យដឹងពីលទ្ធភាពដែលអាចជ្រើសរើស ហើយល្អបំផុតសម្រាប់សេចក្តីត្រូវការរបស់ខ្ញុំ/I will talk to my Counselor and/or visit a District Re-Engagement Center to find out what options are available and best suited to my needs
- ☐ ខ្ញុំនឹង**មិន**រៀនក្នុងកម្មវិធីតាមទម្រង់ផ្សេងទៀត ដើម្បីបញ្ចប់ការសិក្សា ទេ/ I will NOT take an alternative pathway to graduation

**ដំណាក់កាលបន្ទាប់របស់ខ្ញុំ ក្រោយពេលរៀនចប់ពីវិទ្យាល័យ (គូសយកអ្វីៗដែលត្រូវតាមស្ថានភាពរបស់អ្នក)៖**

- ☐ ទៅរៀននៅមហាវិទ្យាល័យ (ពីរឆ្នាំ)/ College (two-year)
- ☐ ទៅរៀននៅមហាវិទ្យាល័យ (បួនឆ្នាំ)/ College (four-year)
- ☐ ទៅរៀននៅសាលាបច្ចេកទេស/Technical school
- ☐ ចូលធ្វើទាហាន/Military
- ☐ បម្រើការងារស៊ីវិល/ Civil Service
- ☐ រៀនធ្វើការជាមួយអ្នកឯកទេស/ Apprenticeship
- ☐ ធ្វើការដើម្បីយកពិសោធន៍/Internship
- ☐ កម្មវិធីផ្តល់ជំនួយ (City Year ។ល។)/ Service program (City Year, etc.)
- ☐ ចូលធ្វើការ/Employment
- ☐ ផ្សេងៗ/Other
- ☐ មិនទាន់ដឹងនៅឡើយ ប៉ុន្តែនឹងស្វែងរកជំនួយពីអ្នកផ្តល់ឱវាទរបស់ខ្ញុំ និងពីអ្នកដទៃទៀត ហើយមើលក្នុង StudentNet ដើម្បីស្វែងយល់បន្ថែមទៀត/ Don't know yet, but will seek help from my Counselor and others, and will visit StudentNet to learn more

**អ្វីៗដែលខ្ញុំបានធ្វើដើម្បីបង់ថ្លៃការសិក្សានៅវិទ្យាស្ថានជាន់ខ្ពស់ (គូសយកអ្វីៗដែលអ្នកបានធ្វើ)៖**

- ☐ បានចូលរួមក្នុងសិក្ខាសាលាស្តីអំពីប្រាក់ជំនួយសម្រាប់បង់ថ្លៃសាលា/Participated in a financial aid workshop
- ☐ បានបំពេញ FAFSA (ពាក្យសុំប្រាក់ជំនួយពីរដ្ឋសហព័ន្ធសម្រាប់បង់ថ្លៃសាលា)/Completed the FAFSA (Free Application for Federal Student Aid)
- ☐ បានប្រើវិបសៃរកអាហារូបករណ៍ និង StudentNet របស់ក្រសួងអប់រំ ដើម្បីស្រាវជ្រាវរក អាហារូបករណ៍ និងប្រាក់ជំនួយ /Used the School District's Scholarship Clearinghouse and StudentNet to research scholarship and grant opportunities
- ☐ បានផ្ញើលិខិតដាក់ពាក្យសុំ អាហារូបករណ៍ និងប្រាក់ជំនួយ/Submitted applications for scholarship and grant awards
- ☐ មិនទាន់បានធ្វើអ្វីៗទាំងនេះនៅឡើយទេ ប៉ុន្តែនឹងស្វែងរកជំនួយពីអ្នកផ្តល់ឱវាទរបស់ខ្ញុំ និងពីអ្នកដទៃទៀត នឹងមើលក្នុង StudentNet ដើម្បីស្វែងយល់បន្ថែមទៀត/Not yet taken any of these steps, but will seek help from my Counselor and others, and will visit StudentNet to learn more

**អ្វីៗដែលខ្ញុំបានធ្វើដើម្បីស្វែងយល់អំពីវិធីទៅរៀននៅមហាវិទ្យាល័យ និងអំពីអាជីព (គូសយកអ្វីៗដែលអ្នកបានធ្វើ)/Steps I've taken to learn about college and career pathways (check all that apply)៖**

- ☐ បានទៅមើលមហាវិទ្យាល័យដែលរៀន ពីរ និង/ឬ បួន ឆ្នាំ/Visited the campus of two and/or four-year college(s)
- ☐ បានទៅមើលសាលាបច្ចេកទេសដែលគេទទួលស្គាល់ជាផ្លូវការ/ Visited the campus of accredited technical schools
- ☐ បានស្រាវជ្រាវរកមហាវិទ្យាល័យ ឬសាកលវិទ្យាល័យ យ៉ាងហោចណាស់បី/Researched at least three colleges or universities
- ☐ បានចូលរួមក្នុងថ្ងៃដើរមើលការងារនៅកន្លែងធ្វើការដើម្បីស្វែងយល់អំពីអាជីព/Participated in a job shadowing day
- ☐ បានចូលរួមក្នុងពិព័ណ៌អាជីព/Participated in a career fair
- ☐ បានស្រាវជ្រាវរក អាជីពផ្សេងៗ និង ការសិក្សា/ការហ្វឹកហ្វឺន ដែលត្រូវការដើម្បីធ្វើឲ្យមានជោគជ័យ យ៉ាងហោចណាស់បី /Researched at least three different careers and the education/training needed for success in each
- ☐ បាននិយាយជាមួយអ្នកធ្វើឯកទេសក្នុងអាជីពដែលខ្ញុំចាប់អារម្មណ៍/ Spoken with professionals in the careers I am interested in
- ☐ បានធ្វើការក្នុងរដូវក្តៅ និង/ឬ ការងារមិនពេញម៉ោងក្រោយម៉ោងសិក្សា/Worked in a summer and/or part-time job after school
- ☐ បានបញ្ចប់កម្មវិធីរៀនធ្វើការដើម្បីយកបទពិសោធន៍/Completed an internship program
- ☐ មិនទាន់បានធ្វើអ្វីៗទាំងនេះនៅឡើយទេ ប៉ុន្តែនឹងស្វែងរកជំនួយពីអ្នកផ្តល់ឱវាទរបស់ខ្ញុំ និងពីអ្នកដទៃទៀត ហើយនឹងមើលក្នុង StudentNet ដើម្បីស្វែងយល់បន្ថែមទៀត/Not yet taken any of these steps, but will seek help from my Counselor and others, and will visit StudentNet to learn more

ការប្រឡងសម្រាប់វិទ្យាស្ថានជាន់ខ្ពស់ដែលខ្ញុំបានប្រឡង (គូសយកអ្វីៗដែលអ្នកបានប្រឡង)/Post-secondary exams I've taken (check all that apply)៖

- ☐ PSAT
- ☐ SAT
- ☐ ACT
- ☐ NOCTI (សម្រាប់សិស្សរៀនយកអាជីព និងបច្ចេកទេស/for Career and Technical Education students)
- ☐ មិនទាន់បានប្រឡងនៅឡើយទេ ប៉ុន្តែនឹងសុំព័ត៌មានពី អ្នកផ្តល់ឱវាទរបស់ខ្ញុំ និងពីអ្នកដទៃទៀត ហើយនឹងមើលក្នុង StudentNet ដើម្បីស្វែងយល់បន្ថែមទៀត/No exams yet taken, but will ask my Counselor and others for information, and will visit StudentNet to learn more

មុខវិជ្ជាដែលខ្ញុំរៀនបានពិន្ទុសម្រាប់ ការសិក្សាកម្រិតខ្ពស់/មហាវិទ្យាល័យ (គូសយកអ្វីៗដែលបានសិក្សា)/Advanced/College credit-bearing courses I've taken (check all that apply)៖

- ☐ កម្មវិធីសិក្សាកម្រិតខ្ពស់/Advanced Placement
- ☐ កម្មវិធីសិក្សាសម្រាប់រៀនយកពិន្ទុបានពីរកន្លែង/Dual Enrollment
- ☐ សញ្ញាប័ត្រទុតិយភូមិអន្តរជាតិ/International Baccalaureate
- ☐ រៀនក្នុងរដូវក្តៅនៅមហាវិទ្យាល័យ/Summer enrollment on college campus
- ☐ មិនបានសិក្សាមុខវិជ្ជាដែលបានពិន្ទុសម្រាប់មហាវិទ្យាល័យទេ/No college credit-bearing courses taken
- ☐ មិនទាន់បានសិក្សាមុខវិជ្ជាអ្វីទេ ប៉ុន្តែនឹងសុំព័ត៌មានពី អ្នកផ្តល់ឱវាទរបស់ខ្ញុំ និងពីអ្នកដទៃទៀត ហើយនឹងមើលក្នុង StudentNet ដើម្បីស្វែងយល់បន្ថែមទៀត/No courses yet taken, but will ask my Counselor and others for information, and will visit StudentNet to learn more

អ្វីៗដែលខ្ញុំបានធ្វើ ដែលនឹងជួយដល់ការចូលរៀន និង/ឬ ការងារ (គូសអ្វីៗដែលអ្នកបានធ្វើ)/Steps I've taken take gain admission and/or employment (check all that apply)៖

- ☐ បានដាក់ពាក្យសុំចូលរៀនទៅ មហាវិទ្យាល័យ និង សាកលវិទ្យាល័យជាច្រើន ដែលត្រូវនឹងជំនាញដែលខ្ញុំចូលចិត្ត/Applied for admission to a range of colleges and universities that are a good fit for me
- ☐ បានដាក់ពាក្យសុំចូលរៀនទៅ សាលាបច្ចេកទេសដែលត្រូវនឹងជំនាញដែលខ្ញុំចូលចិត្ត/Applied for admission to technical school(s) that fit my career interests
- ☐ បានដាក់ពាក្យសុំចូលធ្វើការ ដូចជាក្នុងកម្មវិធី រៀនធ្វើការជាមួយអ្នកឯកទេស រៀនធ្វើការដើម្បីយកបទពិសោធន៍ ការងារស៊ីវិល បម្រើសហគមន៍/Applied for employment opportunities such as an apprenticeship, internship, civil service, community service programs
- ☐ បានដាក់ពាក្យសុំចូលធ្វើទាហាន/Applied for admission to the military
- ☐ មិនទាន់បានបំពេលលិខិតដាក់ពាក្យសុំចូលកន្លែងណានៅឡើយទេ ប៉ុន្តែនឹងរកជំនួយពី អ្នកផ្តល់ឱវាទរបស់ខ្ញុំ និងពីអ្នកដទៃទៀត/ No applications made yet, but will seek help from my Counselor and others
- ☐ ឥឡូវនេះឆាប់ពេល សម្រាប់ការដាក់ពាក្យសុំចូលរៀន (សិស្សថ្នាក់ទី៩-១១)/It is too early to make applications (students in grades 9-11)

## កិច្ចការរបស់សិស្ស/ការវាយតម្លៃផ្សេងទៀត

ជំពូកនេះផ្តល់កន្លែងសម្រាប់សិស្សបញ្ជូនឯកសារតាមកុំព្យូទ័រដែលទាក់ទងនឹង ទិសដៅ និងគម្រោងការណ៍ របស់ពួកគេ។ ឯកសារប្រភេទណាក៏អាចបញ្ជូនបាន ក្នុងចំណុះ 1 MB សម្រាប់សិស្សម្នាក់ ក្នុងមួយឆ្នាំ។ ដើម្បីកុំឲ្យអស់ចំណុះច្រើនសម្រាប់ទុកឯកសារ សិស្សអាចបង្រួញឯកសារជាច្រើនឲ្យតូច (ជាពិសេសឯកសារពីកិច្ចការដែលធ្លាប់បានធ្វើ (portfolio) ឬឯកសារដែលទាក់ទងជាមួយនឹងកិច្ចការតែមួយ) អាចទុកក្នុងកុំព្យូទ័រជុំគ្នា ជាឯកសារ "zip" file។

ទាំងនេះគឺគ្រាន់តែជាឧទាហរណ៍ពីរបីនៃឯកសារដែលសិស្សអាចបញ្ជូនទៅក្នុងជំពូក ILP របស់ពួកគេ៖

- យោបល់ផ្ទាល់ខ្លួន/អត្ថបទសរសេរ សម្រាប់ដាក់ពាក្យសុំ អាហារូបករណ៍ និងដាក់ពាក្យសុំចូលមហាវិទ្យាល័យ
- តំណាងនៃកិច្ចការដែលជាគំរូ សម្រាប់បញ្ចូលក្នុងឯកសារពីកិច្ចការដែលធ្លាប់បានធ្វើ កិច្ចការរៀនសូត្រតាមការអនុវត្តន៍ផ្ទាល់ និង/ឬ កិច្ចការសម្រាប់ឆ្នាំចុងបញ្ចប់
- រូបថត និងកុនខ្លីៗ នៃកម្មវិធីសម្តែងសិល្បៈ
- កិច្ចសន្យាពី វត្តមានអវត្តមាន និងការឈប់គេចសាលា